**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តតាកែវ**

-សំណុំរឿងព្រហ្មទណ្ឌលេខ: ៥៥៧
ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២១
-សាលក្រមព្រហ្មទណ្ឌលេខ: ៥២ "ជ"
ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២២

# សាលក្រម
# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងខេត្តតាកែវ

បានបើកសវនាការជាសាធារណៈនៅសាលាដំបូងខេត្តតាកែវ នាថ្ងៃទី២៥ ខែមេសា ឆ្នាំ ២០២២ វេលាម៉ោង ២ និង ៣០នាទីរសៀល ដោយមានសមាសភាពចូលរួមដូចតទៅ:

## ចៅក្រមជំនុំជម្រះ

លោក [redacted] ចៅក្រមជំនុំជម្រះសាលាដំបូងខេត្តតាកែវ

## តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងខេត្តតាកែវ

## ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តតាកែវ

## ដើម្បីជំនុំជម្រះ

លើសំណុំរឿងព្រហ្មទណ្ឌលេខ: ៥៥៧ ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២១ ដែលមានជនជាប់ចោទ:

-ឈ្មោះ [redacted] សៀងលី ភេទស្រី អាយុ៣៦ឆ្នាំ ជនជាតិខ្មែរ មានទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ននៅភូមិ [redacted] ខេត្តតាកែវ។ (គេចខ្លួន)

ជាប់ចោទពីបទ: **រំលោភលើទំនុកចិត្ត** ប្រព្រឹត្តនៅភូមិថ្មី សង្កាត់កណ្តោលដុំ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ, ភូមិកោះគ្របបាយ ឃុំសំរោង ស្រុកអង្គស្នួល ខេត្តកណ្តាល, ភូមិព្រៃព្រីងត្បូង សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ និងភូមិបូរីកម្មករ សង្កាត់រកាធំ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ កាលពីអំឡុងឆ្នាំ២០១៩ បទល្មើសដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៩១ និងមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ។

-ដោយមានលោកស្រី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សៀងលី។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] អ៊ីលដា ភេទស្រី កើតឆ្នាំ១៩៨២ កាន់អត្តសញ្ញាណប័ណ្ណលេខ: [redacted] សញ្ជាតិខ្មែរ មានទីលំនៅភូមិព្រៃមូល សង្កាត់ក្រាំងធ្នង់ ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

-ដោយមានលោក [redacted] មានអត្តលេខ: [redacted] ជាមេធាវីការពារផលប្រយោជន៍ឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] អ៊ីលដា។

-បានឃើញ ពាក្យបណ្តឹងចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២១ របស់ឈ្មោះ [redacted] អ៊ីលដា។



Scanned with CamScanner

សំណងជំងឺចិត្តចំនួន ១២០,០០០ (មួយសែនពីរម៉ឺន) ដុល្លារអាម៉េរិក ព្រមទាំងសុំឱ្យតុលាការផ្តន្ទាទោសឈ្មោះ [redacted]សៀងលី និងបក្ខពួកទៅតាមច្បាប់។

-លោក [redacted] ជាមេធាវីការពារផលប្រយោជន៍ឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted]លដា បានធ្វើសេចក្តីសន្និដ្ឋានថា: ឈ្មោះ [redacted] សៀងលី ភេទស្រី អាយុ៣៧ឆ្នាំ មានទីលំនៅបច្ចុប្បន្នភូមិប្រហ៊ួត សង្កាត់រកាក្រៅ ក្រុងដូនកែវ ខេត្តតាកែវ ដែលជាស្រីកំណាន់របស់ឪពុកកូនក្តីខ្ញុំបាទឈ្មោះ[redacted] ប៊ុនថុង បានប្រព្រឹត្តបទល្មើសរំលោភលើទំនុក។ ដោយមូលហេតុថាឪពុករបស់កូនក្តីរបស់ខ្ញុំឈ្មោះ [redacted] ប៊ុនថុង អាយុ៦៤ឆ្នាំ មុនពេលគាត់បានស្លាប់ទៅ គាត់បានផ្ទេរប្លង់ដីចំនួន ១៨ប័ណ្ណ ដែលគិតជាទំហំសរុប ៥២ (ហាសិបពីរ) ហិចតា និង ១២៣៦ (មួយពាន់ពីររយសាមសិបប្រាំមួយ) ម៉ែត្រការ៉េ ដែលមានទីតាំងនៅខេត្តកំពង់ស្ពឺ ខេត្តកណ្តាល និងរាជធានីភ្នំពេញ ដូចមាននៅក្នុងឯកសារភ្ជាប់ជាមួយស្រាប់ ព្រមទាំងផ្ទះ និងដីមានទំហំ៥០០ (ប្រាំរយ) ម៉ែត្រការ៉េ ដែលមានទីតាំងស្ថិតនៅភូមិបូរីកម្មករ សង្កាត់រកាធំ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ នៅនឹងឈ្មោះ [redacted] សៀងលី ដែលជាស្រីកំណាន់ឪពុករបស់កូនក្តីខ្ញុំ។ បន្ទាប់មកឈ្មោះ [redacted] សៀងលី បានលក់ផ្ទះ និងដីខាងលើទៅឱ្យឈ្មោះ [redacted] ហៃ និងឈ្មោះ [redacted] ថេងស៊ាង ក្នុងតម្លៃប្រហែលជាង ១១.៧៩០.៣៩០$ (ដប់មួយលានប្រាំពីររយកៅសិប) ដុល្លារអាមេរិក។ ក្នុងរឿងនេះកូនក្តីរបស់ខ្ញុំសុំប្តឹងទាមទារសំណងការខូចខាតចំនួន ១១,៧៩០,៣៩០ (ដប់មួយលានប្រាំពីររយកៅសិប) ដុល្លារអាម៉េរិក និងសំណងជំងឺចិត្តចំនួន ១២០,០០០ (មួយសែនពីរម៉ឺន) ដុល្លារអាម៉េរិក ព្រមទាំងប្តឹងឱ្យតុលាការសម្រេចផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] សៀងលី ទៅតាមច្បាប់។ ដោយសារតែឈ្មោះ [redacted] សៀងលី នេះបានរត់គេចខ្លួនមិនចូលមកដោះស្រាយនោះទេ ហេតុដូច្នេះស្នើសុំឱ្យតុលាការសម្រេចចេញដីកាបង្គាប់ឱ្យចាប់ខ្លួនលើជនជាប់ចោទឈ្មោះ [redacted] សៀងលី តាមបញ្ញត្តិមាត្រា៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

-តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា: ឆ្លងតាមការសួរដេញដោលនាពេលសវនាការរួចទាំងលិខិតគតិយុត្តិនានាបញ្ជាក់ថា: ជនជាប់ចោទឈ្មោះ[redacted]សៀងលី ភេទស្រី អាយុ៣៦ឆ្នាំ ពិតជាបានទទួលការផ្ទេរប្លង់ដី និងផ្ទះរបស់សពឈ្មោះ [redacted] ប៊ុនថុង ដែលត្រូវជាឪពុកបង្កើតរបស់ជនរងគ្រោះឈ្មោះ [redacted] អ៊ីលដា ភេទប្រុស អាយុ៣៤ឆ្នាំ ប្រាកដមែន។ ហេតុនេះតំណាងអយ្យការស្នើសុំដល់លោកចៅក្រមសម្រេចតាមច្បាប់។

-តាមសេចក្តីសន្និដ្ឋានការពារចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២២ របស់លោកស្រី [redacted]ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted]សៀងលី បានសន្និដ្ឋានថា: នាងខ្ញុំសូមបដិសេធការចោទប្រកាន់តាមពាក្យបណ្តឹងរបស់ឈ្មោះ[redacted]អ៊ីលដា ចោលទាំងស្រុង និងសូមធ្វើការបកស្រាយអំពីអង្គហេតុដូចតទៅ: កាលពីថ្ងៃទី៣១ ខែមករា ឆ្នាំ២០២០ សាលាដំបូងខេត្តកំពង់ស្ពឺបានចេញដីកាសម្រេចលេខ: ៦៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០២០ ដែលបានសម្រេច: ១.ទទួលស្គាល់កូនក្តីនាងខ្ញុំឈ្មោះ[redacted]សៀងលី ភេទស្រី កើតថ្ងៃទី០២.០៨. ១៩៨៤ ជនជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ: ១០១០៥០៦៣៦ ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ ២៩១៥ ជាសហព័ទ្ធរបស់មតកជន ([redacted]ប៊ុនថុង) ត្រូវក្លាយជាសន្តតិជនជានិច្ច។ ២.ប្រគល់ដី និងផ្ទះជាមត៌កពីសពឈ្មោះ [redacted]ប៊ុនថុង ដែលមាន: ក.ផ្ទះនិងដីទំហំ ១៦១ ម² ក្បាលដីលេខ ៧២៣ ស្ថិតនៅភូមិពាណិជ្ជកម្ម សង្កាត់រការធំ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ: ០៥០២០៣០២-០៧២៣ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៦, ខ.ដីមានទំហំ ១៩៨៨៦ ម² លេខក្បាលដី ១៤០៩ ស្ថិតនៅភូមិថ្មី



Scanned with CamScanner

ជំ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០៥០២០៣០៣-០១៣១ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៤, ខ.ដីមានទំហំ ៣៣២៩ ម$^{២}$ លេខក្បាលដី ១៤០៤ ស្ថិតនៅភូមិថ្មី សង្កាត់កណ្ដោលដុំ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ: ០៥០២០២០១-១៤០៤ ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៨, គ.ផ្ទះល្វែង ឡូត៍លេខD២៩ ដែលមានទំហំ ៤ម X ១៦ម ស្ថិតនៅក្រុមទី៣ ភូមិឡកំបោរ សង្កាត់ស្វាយប៉ាក ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ដែលមានព្រំប្រទល់ខាងជើងទល់នឹងច្រកផ្លូវ ខាងកើតទល់នឹងផ្ទះលេខD២៧ ខាងត្បូងទល់នឹងផ្លូវ ខាងលិចទល់នឹងផ្ទះលេខD៣១ មានលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី និងផ្ទះសម្បែងលេខ ០៦០ កច្រ១ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៥ ឱ្យមកឈ្មោះ [redacted] សៀងលី កើតថ្ងៃទី០២ ខែសីហា ឆ្នាំ១៩៨៤ ជនជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ: ១០១០៥០៦៣៦ ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៥ ដែលត្រូវជាសហព័ទ្ធរបស់មតកជនឈ្មោះ [redacted] ប៊ុនថុង។ ហើយបន្ទាប់មកទៀតនៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២០ កូនក្ដីនាងខ្ញុំបានលក់អចលនវត្ថុមួយទីតាំងទៅឱ្យឈ្មោះ [redacted] ថេងស្រ៊ាង ដែលមានទំហំ ១៦១ម$^{២}$ លេខក្បាលដី ៧២៣ មានទីតាំងស្ថិតនៅភូមិពាណិជ្ជកម្ម សង្កាត់រកាធំ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ **០៥០២០៣០២-០៧២៣** ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៦ ចេញដោយប្រធានមន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពង់ស្ពឺ ក្នុងតម្លៃសរុប USD ១១៥,០០០ (ដប់មួយម៉ឺនប្រាំពាន់ដុល្លារអាមេរិក)។ ការទិញលក់តាមរយៈកិច្ចសន្យានេះត្រូវបានអនុវត្តចប់សព្វគ្រប់ដោយ [redacted] ថេងស្រ៊ាង បានប្រគល់ប្រាក់គ្រប់ចំនួន ហើយកូនក្ដីនាងខ្ញុំ (ឆាយ សៀងលី) បានផ្ទេរកម្មសិទ្ធិលើអចលនវត្ថុជូន [redacted] ថេងស្រ៊ាង តាមនីតិវិធីសុរិយោដីចប់សព្វគ្រប់។ គួរបញ្ជាក់ផងដែរថាកូនក្ដីនាងខ្ញុំ (ឆាយ សៀងលី) ពិតជាម្ចាស់កម្មសិទ្ធិលើអចលនវត្ថុប្រាកដមែនតាមរយៈដីកាសម្រេចលេខ: ៦៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តកំពង់ស្ពឺ។ ក្រោយមកទៀតកូនក្ដីនាងខ្ញុំ (ឆាយ សៀងលី) បានលក់ដីបន្ថែមដែលគាត់ទទួលបានតាមរយៈដីកាសម្រេចលេខ: ៥៣៤ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២១ ឱ្យទៅ [redacted] ថេងស្រ៊ាង និងលោក [redacted] ហៃ ដោយពួកគាត់បានទិញចូលហ៊ុនគ្នា ទិញនៅថ្ងៃទី០៥ ខែមីនា ឆ្នាំ២០២១។ ដោយ [redacted] ថេងស្រ៊ាង បានចូលហ៊ុនចំនួន ២៥% និងលោក [redacted] ហៃ ចូលហ៊ុនចំនួន ៧៥% ដែលមានទំហំសរុប ៤៥៣០៣៩ ម៉ែត្រការ៉េតម្លៃសរុប ៩០៦,០៧៨$ បានប្រគល់ប្រាក់លើកទី០១ចំនួន ៤០០,០០០$ នៅថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០២០ និងប្រគល់ប្រាក់បង្គ្រប់ ១០០% ចំនួន ៥០៦,០៧៨$ នៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២០។ កាលពីថ្ងៃទី០៥ ខែមីនា ឆ្នាំ២០២១ ជី ហៃ បានទិញអចលន វត្ថុ ០២ ទីតាំង ដែលក្នុងនោះមានអចលនវត្ថុទី០១ មានទំហំ ៥០០ ម$^{២}$ មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០៥០២០៣០៣-០១៣១ ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០២១ មានទីតាំងស្ថិតនៅភូមិបុរីកម្មករ ឃុំរកាធំ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ ក្នុងតម្លៃទិញលក់ ១០៥,០០០$ ដុល្លារអាមេរិក និងអចលនវត្ថុទី២ មានទំហំ ៣៣២៩ ម$^{២}$ មានវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០៥០២០២០១-១៤០៤ ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៨ ក្នុងតម្លៃ ៣ដុល្លារក្នុងមួយម៉ែត្រការ៉េ នាំឱ្យតម្លៃសរុបស្មើនឹង ៩៩៨៧ ដុល្លារអាមេរិក ដូចមានយោងក្នុងកិច្ចសន្យាទិញលក់ដី និងផ្ទះ ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០២១។ ការទិញលក់គឺបានអនុវត្តតាមកិច្ចសន្យាចប់សព្វគ្រប់ ដោយ [redacted] ថេងស្រ៊ាង និង [redacted] ហៃ បានប្រគល់ប្រាក់គ្រប់ចំនួន ហើយកូនក្ដីនាងខ្ញុំបានផ្ទេរកម្មសិទ្ធិជូនពួកគាត់រួចរាល់តាមលក្ខខណ្ឌនៃកិច្ចសន្យា។ ក្រោយទិញដីនេះរួច ពេល [redacted] ថេងស្រ៊ាង និង [redacted] ហៃ ចូលកាន់កាប់ទើបឃើញមាន

ប៊ុនថុង ក៏បានទទួលមរណៈភាពនៅក្នុងមន្ទីរពេទ្យកាល់ម៉ែត្រទៅ។ ហើយក្រោយមកប្លង់ដីចំនួន ១៨ (ដប់ប្រាំបី) ឡូតិ៍, ផ្ទះ ព្រមទាំងដីទំហំ ៥០០ (ប្រាំរយ) ម៉ែត្រការ៉េ ដែលឈ្មោះ [redacted] ប៊ុនថុង បានផ្ញើទុកនៅនឹងឈ្មោះ [redacted] សៀងលី កន្លងមកនោះ គឺត្រូវបានជនជាប់ចោទឈ្មោះ [redacted] សៀងលី ធ្វើការដាក់ពាក្យសុំផ្សេងៗទៅតុលាការដើម្បីស្នើសុំឱ្យតុលាការប្រគល់ឱ្យមកខ្លួន ហើយឈ្មោះ [redacted] សៀងលី ក៏បានធ្វើការកាន់កាប់ ចាត់ចែង និងមិនបានប្រគល់នូវទ្រព្យសម្បត្តិដែលជាមត៌ករបស់ឈ្មោះ [redacted] ប៊ុនថុង ឱ្យទៅក្រុមគ្រួសាររបស់មត៌កជនឈ្មោះ [redacted] ប៊ុនថុង នោះទេ។ ក្រោយមកដើមបណ្តឹងឈ្មោះ [redacted] អ៊ុលដា ដែលត្រូវជាកូនរបស់មត៌កជនឈ្មោះ [redacted] ប៊ុនថុង ក៏បានដាក់ពាក្យបណ្តឹងចូលមកអយ្យការអមសាលាដំបូងខេត្តតាកែវដើម្បីចាត់ការតាមផ្លូវច្បាប់។

៣-យល់ឃើញថា: អំពើប្រព្រឹត្តរបស់ជនជាប់ចោទឈ្មោះ [redacted] សៀងលី ដែលបានគៃបំបាត់យកនូវប្លង់ដីចំនួន ១៨ (ដប់ប្រាំបី) ឡូតិ៍, ផ្ទះ ព្រមទាំងដីទំហំ ៥០០ (ប្រាំរយ) ម៉ែត្រការ៉េ ដែលជារបស់មតក៏ជនឈ្មោះ [redacted] ប៊ុនថុង ត្រូវជាឳពុករបស់ជនរងគ្រោះឈ្មោះ [redacted] អ៊ុលដា ទៅធ្វើការកាន់កាប់ ចាត់ចែង ព្រមទាំងមិនប្រគល់នូវទ្រព្យសម្បត្តិទាំងនោះឱ្យទៅក្រុមគ្រួសាររបស់មត៌កជនឈ្មោះ [redacted] ប៊ុនថុង ដោយចេតនាទុច្ចរិត គឺជាអំពើដែលធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ និងសន្តិសុខសង្គម ជាពិសេសធ្វើឱ្យខាតបង់ និងខូចដល់ទ្រព្យសម្បត្តិដែលជាប្រយោជន៍ស្របច្បាប់របស់អ្នកដទៃទៀតផង ហើយអំពើនេះទៀតសោតត្រូវបានច្បាប់ហាមឃាត់ និងកំណត់ថាជាបទ: **រំលោភលើទំនុកចិត្ត** បទល្មើសដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៩១ និងមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ។

៤-យល់ឃើញថា: ជនជាប់ចោទឈ្មោះ [redacted] សៀងលី ភេទស្រី អាយុ៣៦ឆ្នាំ គឺជានីតិជនមានស្មារតីយល់ដឹង គ្រប់គ្រាន់នូវលទ្ធផលដែលកើតចេញពីអំពើរបស់ខ្លួន និងមានសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌចំពោះអំពើដែលកើតចេញពីអំពើរបស់ខ្លួន។

៥-យល់ឃើញថា: មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] សៀងលី ភេទស្រី អាយុ៣៦ឆ្នាំ ពីបទ: **រំលោភលើទំនុកចិត្ត** ប្រព្រឹត្តនៅភូមិថ្មី សង្កាត់កណ្តោលដុំ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ, ភូមិកោះគ្របបាយ ឃុំសំរោង ស្រុកអង្គស្នួល ខេត្តកណ្តាល, ភូមិព្រៃព្រីងត្បូង សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ និងភូមិបូរីកម្មករ សង្កាត់រកាធំ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ កាលពីអំឡុងឆ្នាំ២០១៩ បទល្មើសដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៩១ និងមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ។

៦-តាមសេចក្តីសន្និដ្ឋានរបស់លោក [redacted] ជាមេធាវីការពារផលប្រយោជន៍ឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] អ៊ុលដា ដោយសុំឱ្យតុលាការសម្រេចអំពីសំណងតាមការទាមទាររបស់កូនក្តីខ្លួន និងសម្រេចអំពីសំណងជំងឺចិត្ត ព្រមទាំងស្នើសុំដល់តុលាការចេញដីកាបង្គាប់ឱ្យចាប់ខ្លួនលើជននេះតាមបញ្ញត្តិច្បាប់។ តុលាការយល់ឃើញថា: ការស្នើសុំនេះមានមូលដ្ឋានតាមផ្លូវច្បាប់ និងមានមូលហេតុសមរម្យ គប្បីតុលាការទទួលយកមកពិចារណា។

៧-តាមការប្តឹងសុំរបស់តំណាងអយ្យការដោយសុំឱ្យតុលាការផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] សៀងលី ពីបទ: **រំលោភលើទំនុកចិត្ត** បទល្មើសដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៩១ និងមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ។ តុលាការយល់ឃើញថា: ការប្តឹងសុំនេះមានមូលដ្ឋានតាមផ្លូវច្បាប់គ្រប់គ្រាន់ គប្បីសម្រេចតាមការប្តឹងសុំ។



Scanned with CamScanner

២-បង្គាប់ឱ្យជនជាប់ចោទឈ្មោះ [redacted] សៀងលី សងប្រាក់ឱ្យទៅដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] អ៊ីលដា ចំនួន ២,៨៩៩,៥៨០ (ពីរលានប្រាំបីសែនប្រាំបួនម៉ឺនប្រាំបួនពាន់ប្រាំរយប៉ែតសិប) ដុល្លារអាម៉េរិក និងសំណងជំងឺចិត្តចំនួន ២០,០០០,០០០ (ម្ភៃលាន) រៀល ការទាមទារលើសពីនេះត្រូវច្រានចោល។

-សាលក្រមនេះបានបើកសវនាការជំនុំជម្រះជាសាធារណៈនៅថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២២ និងប្រកាសជាសាធារណៈនាថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២២ នៅសាលាដំបូងខេត្តតាកែវ កំបាំងមុខដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] អ៊ីលដា និងជនជាប់ចោទឈ្មោះ [redacted] សៀងលី។

-ទុកសិទ្ធិឱ្យប្ដឹងទាស់ និងប្ដឹងឧទ្ធរណ៍នៅក្នុងកំណត់ច្បាប់។

**ក្រឡាបញ្ជីសវនាការ**

ហត្ថលេខា និងត្រា: [redacted]

**ចៅក្រមជំនុំជម្រះ**

ហត្ថលេខា និងត្រា: [redacted]

---

(បានថតចម្លងត្រឹមត្រូវតាមលិខិតដើម)

ថ្ងៃអង្គារ ១៤រោច ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

តាកែវ ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២២

**ក្រឡាបញ្ជីសវនាការ**

[redacted]

បានឃើញ

តាកែវ ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២២

**ចៅក្រមជំនុំជម្រះ**

[redacted]



Scanned with CamScanner